ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៤.....សហវ.ឧ.ក.អគ

ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែឧសភា ឆ្នាំ ២០២៤

# សារាចរ

## ស្តីពី

## ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាថ្នាក់ជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

- យោងព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ៣៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងប្រកាសលេខ ៩២៦ សហវ.ប្រក.អថ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងប្រកាសលេខ ៩២៧ សហវ.ប្រក.អថ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនិងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- យោងការសម្រេចយល់ព្រមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០២៤ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនិងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ត្រូវបានធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០២៣ ដោយបានព្យាករតាមសេណារីយ៉ូមួយមានលក្ខណៈសុទិដ្ឋិនិយមថា សេដ្ឋកិច្ចកម្ពុជាអាចនឹងមានកំណើនក្នុងអត្រា ៦,៦% លើមូលដ្ឋាននៃដោយរំពឹកទុកនូវភាពប្រសើរឡើងនៃសេដ្ឋកិច្ចកម្ពុជាក្រោយការបោះឆ្នោតសកល ជាពិសេសការងើបឡើងវិញនៃវិស័យទេសចរណ៍ក្រោយវិបត្តិកូវីដ-១៩។ ជាលទ្ធផល គម្រោងថវិកាឆ្នាំ ២០២៤ ក៏ត្រូវបានគិតគូរតាមសេណារីយ៉ូចំណូលដែលមានសុទិដ្ឋិនិយមនេះដែរ ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការចំណាយលើអាទិភាពគោលនយោបាយថ្មី ដែលគ្រោងនឹងអនុវត្តចាប់ពីដើមនីតិកាលទី៧ នៃរដ្ឋសភា។ ទោះបីជាយ៉ាងនេះក្តី, ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចសកលមានភាពមិនប្រាកដប្រជាខ្ពស់, រាជរដ្ឋាភិបាលក៏បានគិតទុកជាមុនដែរថា កម្ពុជាអាចនឹងបន្តជួបប្រទះនឹងហានិភ័យ និងបញ្ហាប្រឈមចម្បងៗ ជាពិសេសពីកត្តាខាងក្រៅ ដែលអាចធ្វើឱ្យកំណើនខាងលើនេះមិនអាចសម្រេចបានតាមការគ្រោងទុក ដែលក្នុងនោះមានជាអាទិ៍៖ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, ការបែកខ្ញែកពាណិជ្ជកម្ម/សេដ្ឋកិច្ច, និន្នាការថមថយនៃកំណើនសេដ្ឋកិច្ចសកល, ភាពមិនច្បាស់លាស់នៃទស្សនវិស័យសេដ្ឋកិច្ចចិន ក៏ដូចជាការបន្តរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក ដែលការណ៍នេះនឹងបង្កផលប៉ះពាល់អវិជ្ជមានដល់ស្ថានភាពនៃការប្រមូលចំណូលថវិការដ្ឋ ។

នាពេលនេះ សេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២៤ ជារួម ត្រូវបានវាយតម្លៃថានឹងមានកំណើនក្នុងអត្រា ៦,០% ធៀបនឹងកំណើនក្នុងរង្វង់ ៥,០% នៅក្នុងឆ្នាំ ២០២៣ ដែលទាបជាងការព្យាករកាលពីពាក់កណ្តាលឆ្នាំ ២០២៣។ ជាក់ស្តែង ការងើបឡើងវិញនៃវិស័យទេសចរណ៍មានល្បឿនយឺតជាងការរំពឹងទុកខ្លាំង ចាប់ពីអំឡុងឆមាសទី២ ឆ្នាំ ២០២៣ ហើយបន្តមកដល់ឆ្នាំ ២០២៤ នេះ។ ជាមួយនឹងនិន្នាការកំណើនសេដ្ឋកិច្ចនេះ ក្នុងស្មារតីគ្រប់គ្រងថវិកាប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធ្វើការវាយតម្លៃ និងប៉ាន់ស្មានឡើងវិញអំពីការអនុវត្តចំណូលថវិការដ្ឋឆ្នាំ២០២៤ ដោយផ្អែកលើលទ្ធផលនៃការអនុវត្តចំណូលត្រីមាសទី ១ ឆ្នាំ ២០២៤ ដែលជារួមឃើញថា ចំណូលចរន្តថវិការដ្ឋមាននិន្នាការថមថយ ហើយហូតដល់ដំណាច់ឆ្នាំ អាចនឹងសម្រេចបានទាបជាងផែនការដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៤។ ចំពោះ ផ្នែកចំណាយវិញ, រាជរដ្ឋាភិបាលក៏មានតម្រូវការថវិកាធំក្នុងការអនុវត្តគោលនយោបាយថ្មី រួមទាំងចំណាយផ្នែកគាំពារសង្គម ការជួយគាំពារ និងការសម្រួលបរិយាកាសធុរកិច្ច ក៏ដូចជាការជំរុញការវិនិយោគក្នុងស្រុក តាមរយៈការលើកទឹកចិត្ត ការលើកលែង ឬបន្ធូរបន្ថយកាតព្វកិច្ចផ្នែកពន្ធដារ និង ផ្នែកគយ និងរដ្ឋាករ ។

ជារួម ថ្វីដ្បិតតែគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកទឹកចិត្ត ការលើកលែង និងការបន្ធូរបន្ថយកាតព្វកិច្ចផ្នែកពន្ធដារ និង ផ្នែកគយនិងរដ្ឋាករ មួយចំនួនធំបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការស្តារ និងការជំរុញកំណើនសេដ្ឋកិច្ច និងការបង្កើតការងារជូនប្រជាជន តែក៏បានធ្វើឱ្យចំណូលចរន្តមានការថមថយគួរឱ្យកត់សម្គាល់ ហើយមិនមានសង្គតិភាពទាំងស្រុងជាមួយនឹងកំណើនសេដ្ឋកិច្ច, ជាពិសេស ផ្នែកចំណូលសារពើពន្ធ ដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទោះបីអគ្គនាយកដ្ឋានទាំងពីរបានខិតខំពង្រឹងការអនុវត្តវិធានការម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងទាំងតាមវិធានការគោលនយោបាយក្តី។

ក្នុងន័យនេះ, បន្ទាប់ពីបានគិតគូរ និងថ្លឹងថ្លែងយ៉ាងហ្មត់ចត់ ដោយផ្អែកលើស្ថានភាពនៃការអនុវត្ត ការប្រមូលចំណូល គិតត្រឹមដំណាច់ខែ មីនា ឆ្នាំ ២០២៤ និងស្ថានភាពនៃតម្រូវការផ្អែកចំណាយរហូតដល់ដំណាច់ឆ្នាំ ២០២៤, និងបន្ថែមលើវិធានការបឋមនៃការធ្វើវិចារណកម្មចំណាយដែលត្រូវបានកំណត់ក្នុង សារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ផ្អែកតាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**, សូមដាក់ចេញនូវវិធានការវិចារណកម្មព្យួរផលានទានចំណាយថវិកាថ្នាក់ជាតិ និង វិធានការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ដូចខាងក្រោម៖

## ១- ការធ្វើវិចារណកម្មចំណាយចរន្តថវិកាថ្នាក់ជាតិ ផ្នែកចំណាយមិនមែនបន្ទុកបុគ្គលិករបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាល

### ក- ស្ថាប័ន និងអង្គភាព ដែលត្រូវបានលើកលែងការធ្វើវិចារណកម្មចំណាយ

ការធ្វើវិចារណកម្មចំណាយថវិកាឆ្នាំ ២០២៤ ត្រូវបានលើកលែង ដូចខាងក្រោម ៖

- ព្រឹទ្ធសភា, រដ្ឋសភា, ក្រុមប្រឹក្សាធម្មនុញ្ញ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)
- គ្រឹះស្ថានសាធារណៈរដ្ឋបាល, អង្គភាពជាក្រុមប្រឹក្សា, អាជ្ញាធរ និងគណៈកម្មាធិការនានារបស់រាជរដ្ឋាភិបាលដែលមានកញ្ចប់ថវិកាដោយឡែក ស្ថិតក្រោមក្រសួង-ស្ថាប័នពាក់ព័ន្ធ
- កញ្ចប់ចំណាយថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត និង កញ្ចប់ថវិកាសម្រាប់មុខងារដែលបានប្រគល់ដោយមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និង វិស័យអប់រំ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត និងសាលាឧទ្ធរណ៍តំបន់ទាំង៤

### ខ. មុខសញ្ញាចំណាយ ដែលត្រូវបានលើកលែងការធ្វើវិចារណកម្មចំណាយ

ការធ្វើវិចារណកម្មចំណាយ ត្រូវបានលើកលែងចំពោះមុខសញ្ញាចំណាយដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័នមួយចំនួន ដែលមានលក្ខណៈជាគោលរបប និង/ឬមានភាពចាំបាច់ខ្ពស់ ដូចខាងក្រោម៖

- ការទិញអង្ករ និងឯកសណ្ឋានរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ
- ការទិញប្រេងឥន្ធនៈ របស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ
- ការបោះពុម្ពសៀវភៅគោល និងកម្មសិទ្ធិបញ្ញារបស់ក្រសួងអប់រំ យុវជន និងកីឡា
- ការបោះពុម្ពសៀវភៅសុខភាពមាតា, បណ្ណលឿងចាក់ថ្នាំកុមារ និងសៀវភៅអប់រំសុខភាពមាតា (ពីពេលពិនិត្យផ្ទៃពោះ រហូតដល់ក្រោយសម្រាល) របស់ក្រសួងសុខាភិបាល
- ការបោះពុម្ពតែមពន្ធគយ និងពន្ធដាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបម្រើឱ្យគោលដៅប្រមូលចំណូល
- ការជួសជុល និងថែទាំផ្លូវថ្នល់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ, ព្រមទាំងការជួសជុល និង ថែទាំប្រព័ន្ធធារាសាស្ត្ររបស់ក្រសួងធនធានទឹក និងឧតុនិយម
- កាតព្វកិច្ចទូទាត់ពហុឆ្នាំ សម្រាប់កិច្ចសន្យានានាដែលបានចុះរួចហើយ

### គ- ការធ្វើវិចារណកម្មចំណាយមិនមែនបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល

ការធ្វើវិចារណកម្មចំណាយ ត្រូវបានអនុវត្តសម្រាប់គ្រប់ក្រសួង ស្ថាប័ន, លើកលែងតែស្ថាប័ន និងអង្គភាព ដែលបានកំណត់ក្នុងចំណុច "**ក**", តាមគោលការណ៍ និង លើមុខចំណាយ ដូចខាងក្រោម ៖

• កាត់ព្យួរឥណទាន ២៥% នៃទំហំឥណទានសរុប លើមុខសញ្ញាចំណាយនៃការទិញទំនិញ (ជំពូក ៦០) ដែលរួមមាន៖ (១)-សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ, (២)-សម្ភារផ្គត់ផ្គង់ថែទាំអគារ ប្រាសាទ និង សំណង់, (៣)-សម្ភារផ្គត់ផ្គង់ថែទាំសម្ភារឧបករណ៍, (៤)-ប្រេងឥន្ធនៈគ្រប់ប្រភេទ, (៥)-សម្ភារការិយាល័យ, (៦)-ការបោះពុម្ព, (៧)-សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា, (៨)-សង្ហារិម, (៩)-សម្ភារប្រើប្រាស់, (១០)-សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា; និង (១១)-មុខសញ្ញាចំណាយដទៃផ្សេងទៀត ដែលបានផ្តល់ជានាចំណាយជំហានទី ១ ចំនួន ៥០% រួចហើយ;

• កាត់ព្យួរឥណទាន ២៥% នៃឥណទានសរុប លើមុខសញ្ញាចំណាយនៃការទិញសេវាកម្មផ្សេងៗ (ជំពូក ៦១) ដែលពាក់ព័ន្ធនឹងសេវាថែទាំ និងជួសជុលផ្សេងៗ រួមមាន៖ (១)-ការថែទាំ ជួសជុលអគារ និងប្រាសាទ, (២)-ការថែទាំបណ្តាញផ្សេងៗ, (៣)-ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន និង (៤)-ការថែទាំ និងជួសជុលសម្ភារ និងឧបករណ៍ បច្ចេកទេស;

• កាត់ព្យួរឥណទាន ១៥% នៃឥណទានសរុប លើមុខសញ្ញាចំណាយ (ជំពូក ៦១) រួមមាន៖ (១)-ប្រជុំ សិក្ខាសាលា និងសន្និសីទ, (២)-សោហ៊ុយបេសកកម្មក្នុងប្រទេស (សោហ៊ុយស្នាក់នៅ, សោហ៊ុយដឹកជញ្ជូន និងប្រាក់ហោប៉ៅ) ដោយលើកទឹកចិត្តប្រើប្រព័ន្ធ online (zoom) ជំនួសតាមករណីដែលអាចធ្វើបាន;

• បង្កកឥណទានចំណាយប្រមាណ ២០០ ប៊ីលានរៀល (ក្នុងអនុគណនី ៦២០២៨) ដែលជាចំណាយត្រៀមបម្រុងរបស់រាជរដ្ឋាភិបាល បានគ្រោងទុកនៅក្នុងកញ្ចប់ថវិកាក្រសួងសុខាភិបាល សម្រាប់ដោះស្រាយបញ្ហាវិបត្តិជំងឺសកល ដែលអាចកើតឡើងជាយថាហេតុ។

ផ្អែកលើគោលការណ៍កាត់ព្យួរឥណទានខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំជាតារាងឧបសម្ព័ន្ធជូនគ្រប់ក្រសួង-ស្ថាប័ន អំពីទំហំឥណទានដែលត្រូវធ្វើវិចារណកម្មចំណាយ និងឥណទានដែលនៅមានសម្រាប់បន្តបញ្ជាចំណាយបាន។ លើមូលដ្ឋាននេះ, ក្រសួង-ស្ថាប័នចាំបាច់ត្រូវកែតម្រូវទំហំឥណទានសរុប រួមទាំងតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានរបស់ខ្លួន ទៅតាមទំហំនៃមុខសញ្ញាចំណាយទាំងអស់ដែលបានកាត់សន្សំព្យួរខាងលើ និងទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពពាក់ព័ន្ធ ។

## ២- ការធ្វើវិចារណកម្មចំណាយមូលធនថវិកាថ្នាក់ជាតិ

ការធ្វើវិចារណកម្មចំណាយ ត្រូវបានអនុវត្តលើឥណទានចំណាយគម្រោងវិនិយោគសាធារណៈ ដូចខាងក្រោម៖

• កាត់ព្យួរឥណទានចំណាយវិនិយោគសម្រាប់អនុវត្តការងារហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានការសម្រេចរួចហើយពីរាជរដ្ឋាភិបាលរបស់ក្រសួងចំនួន ៤ ដែលមានឥណទានសរុប ៨៧ ០០០ លានរៀល ក្នុងនោះ៖ ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ២២ ៥០០ លានរៀល, ក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ៣៧ ៥០០ លានរៀល, ក្រសួងធនធានទឹក និងឧតុនិយម ចំនួន ១៨ ០០០ លានរៀល, និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៩ ០០០ លានរៀល;

• កាត់ព្យួរឥណទានចំណាយត្រៀមបម្រុងមានមុខសញ្ញា សរុបចំនួន ៨៩៦ ៦៩០ លានរៀល ក្នុងនោះ៖ បញ្ចប់កម្មវិធីសាច់ប្រាក់សម្រាប់ពលកម្មចំនួន ២០៥ ០០០ លានរៀល (ដោយបញ្ចប់ការអនុវត្ត), មូលនិធិបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ចំនួន ៤ ០០០ លានរៀល, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល

និងបៃតង ចំនួន ១២១ ៩៥០ លានរៀល, ការទូទាត់ស្ពានឆ្លងកាត់ទន្លេមេគង្គជីផង្គ-ថ្មគរ (ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត) ចំនួន ៤៧០ ០០០ លានរៀល (ដោយផ្ទេរទៅប្រើមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយថវិកាដៃគូ អភិវឌ្ឍន៍), ចំណាយត្រៀមបម្រុងសម្រាប់អន្តរាគមន៍ចាំបាច់ផ្សេងៗចំនួន ៦១ ៣០០ លានរៀល និង ចំណាយសម្រាប់ឱ្យរដ្ឋាករទឹកខេត្តសៀមរាបខ្ចី ចំនួន ៣៤ ៤៤០ លានរៀល (ដោយផ្ទេរទៅប្រើមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយថវិកាដៃគូអភិវឌ្ឍន៍) ;

- កាត់ឥណទានចំណាយត្រៀមបម្រុងផ្សេងៗ និងមិនបានគ្រោងទុក ចំនួន ១៥០ ០០០ លានរៀល ក្នុងនោះ៖ ចំណាយត្រៀមបម្រុងមិនបានគ្រោងទុក ចំនួន ៥០ ០០០ លានរៀល និងចំណាយសម្រាប់ទូទាត់គម្រោងដែលបានធានាចំណាយពីឆ្នាំមុនៗ ចំនួន ១០០ ០០០ លានរៀល។

ជាមួយនឹងការកាត់សន្សំឥណទានរបស់ ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងរៀបចំជាតារាងឧបសម្ព័ន្ធជូនទៅក្រសួងពាក់ព័ន្ធទាំង ៤ ដែលរំលេចអំពីទំហំឥណទានដែលត្រូវបានធ្វើវិចារណកម្មចំណាយ និងឥណទានដែលនៅសល់ក្រោយការធ្វើវិចារណកម្មរបស់ក្រសួងនីមួយៗសម្រាប់បន្តបញ្ជាចំណាយបាន។ លើមូលដ្ឋាននេះ, ក្រសួងទាំង ៤ ចាំបាច់ត្រូវធ្វើអាទិភាវូបនីយកម្មគម្រោងឡើងវិញទៅតាមកម្រិតឥណទានថវិកាដែលមាន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្អាកការផ្តល់ធានាចំណាយគម្រោងត្រៀមបម្រុង។ ក្នុងករណីចាំបាច់, សម្រាប់គម្រោងថ្មី ដែលមានចរិតទ្រទ្រង់ជម្រើមសេដ្ឋកិច្ចក្នុងស្រុក, គម្រោងស្តារឡើងវិញដែលខូចខាតដោយទឹកជំនន់ក្នុងឆ្នាំ២០២៤, គម្រោងពហុឆ្នាំដែលផ្តល់ផលប្រយោជន៍សេដ្ឋកិច្ច និងគម្រោងវិនិយោគដែលមានចរិតយុទ្ធសាស្ត្របម្រើ ដល់គោល-នយោបាយវិស័យកសិកម្ម ត្រូវបានផ្តល់អាទិភាពក្នុងការស្នើសុំការសម្រេចដោយឡែកទៅតាមករណី និងតាមលទ្ធភាពថវិកាជាក់ស្តែង។

## ៣-វិធានការបន្ថែមសម្រាប់ការពង្រឹងប្រសិទ្ធភាពចំណាយ

ដើម្បីអនុវត្តវិធានការវិចារណកម្មចំណាយឆ្នាំ ២០២៤ ឱ្យមានប្រសិទ្ធភាពខ្ពស់, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមដាក់ចេញនូវវិធានការបន្ថែមសម្រាប់ពង្រឹងប្រសិទ្ធភាពចំណាយ ដូចតទៅ៖

- ✓ មិនផ្តល់ភាពទន់ភ្លន់ក្នុងការផ្តល់បុរេប្រទាន និងនិយ័តភាពផ្ទៃក្នុងបំពេញការខ្វះខាតរបស់ក្រសួង-ស្ថាប័ន ដោយប្រើឡើងវិញនូវឥណទានកាត់សន្សំពីធានាចំណាយឡើយ លើកលែងតែមានករណីចាំបាច់ដោយឡែកខានមិនបានពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយថ្មី និង/ឬការសម្រេចថ្មីៗរបស់រាជរដ្ឋាភិបាល។
- ✓ រឹតបន្តឹងការត្រួតពិនិត្យចំណាយ ដោយមិនអនុញ្ញាតឱ្យចំណាយលើសកម្មភាពណាដែលមិនសូវចាំបាច់ មិនទាន់ចាំបាច់ និងលែងចាំបាច់ដើម្បីទុកឥណទានដោះស្រាយចំណាយដែលចាំបាច់ខ្លាំង។
- ✓ មិនផ្តល់បុរេប្រទាន ដោយគ្មានឥណទាន និង/ឬ បន្ថែមឥណទាន លើកលែងតែមានការសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង/ឬពីប្រមុខរាជរដ្ឋាភិបាល។

ការធ្វើវិចារណកម្មព្យួរឥណទានចំណាយ និងវិធានការពង្រឹងប្រសិទ្ធភាពចំណាយដែលបានដាក់ចេញខាងលើ ត្រូវបានគិតគូររៀបចំក្នុងក្របខ័ណ្ឌនៃការធានាប្រក្រតីភាពនៃស្ថាប័នរដ្ឋ រក្សាបាននូវគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងក្នុងស្មារតីធានាឱ្យបាននូវការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកាឆ្នាំ ២០២៤ ។

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ និងអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គនាយកដ្ឋានថវិកា
- គ្រឹះស្ថានសាធារណៈរដ្ឋបាល
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ